**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៥ អនក្រ.បក

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
មកដល់ៈថ្ងៃទី 16 ខែ 01 ឆ្នាំ២០25
ម៉ោង 10:00 លេខ 104 ក.អ.ក
រដ្ឋបាល ក.អ.ក

# អនុក្រឹត្យ

# ស្តីពី

# ការកែសម្រួលឧបសម្ព័ន្ធទី១ (បញ្ជីអវិជ្ជមាន) និង ឧបសម្ព័ន្ធទី២ (បញ្ជីបែងចែកក្រុមនៃសកម្មភាពវិនិយោគ) នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



ទ

- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រាមួយ .-**

លេខរៀង គ.៤៧ (កម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម) ផ្នែក គ (សកម្មភាពវិនិយោគ ឬក្រុមសកម្មភាពវិនិយោគក្នុងវិស័យឧស្សាហកម្ម) នៃឧបសម្ព័ន្ធទី១ (បញ្ជីអវិជ្ជមាន) និងលេខរៀងទី៣ (កម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម) ផ្នែកទី២ (ក្រុមសកម្មភាពវិនិយោគទី២ (ក្រុម២)) នៃឧបសម្ព័ន្ធទី២ (បញ្ជីបែងចែកក្រុមនៃសកម្មភាពវិនិយោគ) នៃអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

- លេខរៀង គ.៤៧ ថ្មី (កម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម) ផ្នែក គ (សកម្មភាពវិនិយោគ ឬក្រុមសកម្មភាពវិនិយោគក្នុងវិស័យឧស្សាហកម្ម) នៃឧបសម្ព័ន្ធទី១ (បញ្ជីអវិជ្ជមាន) ត្រូវបានកែប្រែដូចមាននៅក្នុងតារាងខាងក្រោម៖

| **គ. សកម្មភាពវិនិយោគ ឬក្រុមសកម្មភាពវិនិយោគក្នុងវិស័យឧស្សាហកម្ម** | | | |
|---|---|---|---|
| លរ. | សកម្មភាពវិនិយោគ ឬក្រុមសកម្មភាពវិនិយោគ | | លក្ខណៈវិនិច្ឆ័យ |
| គ.៤៧ ថ្មី | កម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម | | |
| | គ.៤៧.១ | កម្មន្តសាលភេសជ្ជៈ ក្រៅពីស្រាបៀរ | ទុនវិនិយោគសមមូលទាបជាង ៥០០ ០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក |
| | គ.៤៧.២ | កម្មន្តសាលស្រាបៀរបម្រើទីផ្សារក្នុងស្រុក | |
| | គ.៤៧.៣ | កម្មន្តសាលស្រាបៀរបម្រើឱ្យការនាំចេញ | ទុនវិនិយោគសមមូលទាបជាង ៥០០ ០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក |

- លេខរៀងទី៣ ថ្មី (កម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម) ផ្នែកទី២ (ក្រុមសកម្មភាពវិនិយោគទី២ (ក្រុម២)) នៃឧបសម្ព័ន្ធទី២ (បញ្ជីបែងចែកក្រុមនៃសកម្មភាពវិនិយោគ) ត្រូវបានកែប្រែដូចមាននៅក្នុងតារាងខាងក្រោម៖

| **លរ.** | **សកម្មភាពវិនិយោគ** | | **លេខកូដ** (ISIC Code) |
|---|---|---|---|
| ៣ ថ្មី | កម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម | | |
| | ៣.១ | កម្មន្តសាលភេសជ្ជៈ ក្រៅពីស្រាបៀរ | |
| | ៣.២ | កម្មន្តសាលស្រាបៀរបម្រើឱ្យការនាំចេញ | |



ៗ

**មាត្រាពីរ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាពីរ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ